D03023
TSL ~~Box 16~~
ឋ- 5466

អំពីឈ្មោះ ទុង

លេខាវរសេនាតូច ១១៩ កងពល ១៤

ចម្លើយៈ សេង.សឿន កងផលិត តំបន់ ២៥ ។

---

១ - ប្រវត្តិនយោបាយរបស់ ឪពុកម្ដាយទុង គឺ ជាគ្រួសារ ១ ដែលស្អប់ ចលនា បដិវត្តតាំងពី ដើមរៀងមក ។

២ - ទុង ចូលបដិវត្តជាមួយវៀតណាម ។ សំណប់ចិត្តជាមួយពួកវៀតណាម - វាអត់បញ្ជាក់ឈ្មោះទេ - ។

៣ - យុទ្ធមិត្តដែលចូល បដិវត្តជំនាន់វៀតណាមចូលស្រុក ត្រូវណាស់អ្នកដែល ដឹងអំពីផែនការរបស់បក្សពលករវៀតណាមចំពោះ ប.ក.ក. តែ ទុង ដឹងអំពីផែនការនេះ ។ សេង.សឿនវាមិនបញ្ជាក់ ល្អិតអំពីផែនការវៀតណាមដែលទុងដឹងទេវាគ្រាន់តែឮទុងថាៈ " ពេលចប់សង្គ្រាមជាមួយពួកលន់-ណុល គឺត្រូវ មានសង្គ្រាមទៀត "។

៤ - កាលនៅសមរភូមិអង្គការសិត ទុងដកទ័ពរត់ចោលខ្មែរក្រហម ។ ពេលប្រជុំដកពិសោធន៍ សមូហភាពសុំឱ្យដកទុងចេញ-ខ្លះសុំកំទេច- ។

តែស៊ឿន ធានា កសាងបន្ត ដើម្បីឱ្យខ្លួនទៅជាកំលាំង ក្នុងសកម្មភាព ត្រៀមវាយ បក្ស ។

៥ - ខ្លួន និង ស៊ឿនទាក់ទងគ្នាជាប់តាំងពីក្នុងសង្គ្រាមរហូតបច្ចុប្បន្ន ។ ក្រោយ ១៧ ស៊ឿន ទាក់ទងខ្លួនជាប់ក្នុងផែនការ កសាងកំឡាំង ត្រៀមវាយបក្ស ទៅថ្ងៃអនាគត ។ - អត់បញ្ជាក់ពេល វេលាទេ -

៦ - ឥឡូវ ខ្លួន ត្រូវអង្គការ ចាត់តាំងឱ្យទៅការពារទល់ដែន - កងពល ១៥ បងវឿន - មុនចេញដំណើរទៅ ខ្លួននិងស៊ឿនជួបគ្នាទៀត ។ ស៊ឿន ណែនាំ ខ្លួនអំពី : កុំភ្លេចអំពីការកសាងកម្លាំង ផែនការវាយបក្ស ការតភ្ជាប់ខ្សែស៊ឿនពុំបានសិតបញ្ជា និមួយៗទៀត- ។ ខ្លួន វាគ្រាន់តែបញ្ជាក់ប្រាប់ស៊ឿនថា: ពេលកងទ័ពវៀតណាមវាយលុកគេ- ខ្លួន នឹងបញ្ជាទ័ពឱ្យនៅខាងវៀតណាម ព្រោះអង្គភាពគេស្ទាប់ទៅជាមួយវៀតណាមស្រាប់ ។

៧ - ខ្លួនជាគណៈ វ.ត ១១៩ កាលនៅតំបន់ ២៥ ។

ខ្លួន អាចជាមនុស្សរបស់ពួកសុខផងក៏មិនដឹង ។

៨ - តែគួរឱ្យចម្លែកដែរ ពួកអ៊ំ. ស៊ឿន -សៅតា ដែលយើងចាប់មក

ពីកង៣៧ ៥០២ វានិយាយដាក់តែគ្នាថា ដែលសុខចាត់តាំងបង្កប់ មកក្នុងទ័ពភាគពិសេសឆ្នាំ ៧៤ ។ ចំណែកពួក ១១៩ ដែលសុខចាត់តាំងឱ្យទៅខាងនីរតីតាំងពី ៧៣ - រប ៥២អត់ទាន់ដក - ពួក ៥០២ ៧០៣ ពួកមូលដ្ឋាន ២៥ អត់នរណាឆ្លើយប៉ះទុង ដែលសុខចាត់តាំងបង្កប់ ជំនាន់នោះនោះ ។ យើងឬ សង្ស័យសុខណែនាំពួក ៥០២ ៧០៣ ២៥ កុំឱ្យនិយាយប៉ះពួក ១១៩ផងក៏មិនដឹង ។ ព្រោះកង ១១៩ កាលនៅ ២៥ គេចាត់ទុកជាកម្លាំងល្អបំផុតរបស់តំបន់ឬ គេនិយមទៅថាអង្គភាព យានមុខ ។

៚